**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០១២/០៧/២០០៨ កបធ.សជណ                    រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៨

**ជម្រាបមក**

**លោក ហ៊ីង យឿន**

**កម្មវត្ថុ** : រឿងទាក់ទងនឹងបណ្តឹងរបស់លោក ហ៊ីង យឿន ប្តឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានបដិសេធមិនទទួលយកពាក្យបណ្តឹងលេខ ០៩៤ កទដប ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០០៨ មកធ្វើការដោះស្រាយ

**យោង** : បណ្តឹងគ្មានលេខ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ របស់លោក ហ៊ីង យឿន ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ៦៩ $AE_3$ ភូមិ ៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ក្រុងភ្នំពេញ

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបមក លោក ហ៊ីង យឿន ជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៨ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យលើបណ្តឹងរបស់លោករួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ពុំអាចលើកយកបណ្តឹងនេះមកពិភាក្សា និង សម្រេចបានឡើយ ពីព្រោះបណ្តឹងរបស់លោកមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា ២៥ថ្មី មាត្រា ២៦ និងមាត្រា ២៧ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង មាត្រា ៧៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នោះទេ ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**